នីតិវិធីនៃការការពារសិទ្ធិ បានរៀបរាប់អំពីសិទ្ធិរបស់ មាតាបិតា/អាណាព្យាបាល ដែលមានកូនពិការ និង វិធីសាស្ត្រដែលការពារសិទ្ធិទាំងនេះ ក្រោមច្បាប់របស់ រដ្ឋ និង រដ្ឋសហព័ន្ធ។ សិទ្ធិសំខាន់ៗរបស់ មាតាបិតា/អាណាព្យាបាល មួយចំនួន ត្រូវបានលើកយកមកបញ្ជាញនៅខាងក្រោមនេះ ព្រមទាំងការណែនាំសម្រាប់ មាតាបិតា/អាណាព្យាបាល ដែលភាសាអង់គ្លេសមិនមែនជាភាសាកំណើត អាចត្រូវការស្នើសុំជំនួយផ្នែកបកប្រែភាសាពី ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

- សិទ្ធិក្នុងការរក្សាការសម្ងាត់ និង ត្រួតពិនិត្យ និង ពិនិត្យឡើងវិញនូវ សំណុំឯកសារនៃការសិក្សារបស់កូនលោកអ្នក។
- សិទ្ធិក្នុងការ ផ្តល់ ឬ បដិសេធ ការយល់ព្រមរបស់លោកអ្នកមុននឹង ការវាយតម្លៃ ការវាយតម្លៃឡើងវិញ និង ការចាត់តាំងឲ្យចូលក្នុងកម្មវិធីអប់រំពិសេស ដំបូង។
- សិទ្ធិចូលរួមក្នុងកិច្ចប្រជុំដែលទាក់ទងនឹង ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និង ការចាត់តាំង កូនរបស់លោកអ្នក និង ការផ្តល់ការអប់រំសាធារណៈដែលសមស្រប ដោយឥតគិតថ្លៃ (FAPE) ដល់កូនរបស់អ្នក។
- សិទ្ធិនៃការទទួលដំណឹងជាលាយលក្ខណ៍អក្សរជាមុនអំពី ការផ្លាស់ប្តូរកម្មវិធីអប់រំ ឬ គម្រោងការសិក្សាសម្រាប់សិស្សម្នាក់ៗ (IEP) របស់កូនលោកអ្នក។
- សិទ្ធិទទួលបាន ការអប់រំសាធារណៈដែលសមស្រប ដោយឥតគិតថ្លៃ (FAPE) សម្រាប់កូនលោកអ្នក ដែលលោកអ្នកមិនបាច់បង់ប្រាក់។
- សិទ្ធិក្នុងការឱ្យកូនរបស់លោកអ្នក ចូលរៀន ចូលរួមក្នុងសកម្មភាព ដែលមិនមែនជាការសិក្សា និង ក្រៅម៉ោងសិក្សា និង ទទួលសេវាកម្មជាមួយកុមារដែលមិនពិការ ជាអតិបរមា ទៅតាមលក្ខណៈសមរម្យ។
- សិទ្ធិក្នុងការស្នើសុំសវនាការតាមច្បាប់នៃការគោរពសិទ្ធិរបស់បុគ្គលដោយមិនលម្អៀង ប្រសិនបើលោកអ្នកមិនយល់ស្រប ជាមួយក្រុម IEP អំពី ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ឬ ការចាត់តាំង កូនរបស់លោកអ្នក ឬ ការផ្តល់ FAPE ដល់កូនរបស់លោកអ្នក។
- សិទ្ធិដកហូតកិច្ចព្រមព្រៀងសម្រាប់ការផ្តល់ ការអប់រំពិសេស និង ជំនួយដែលពាក់ព័ន្ធ ដ៏ទៃទៀត។
- សិទ្ធិក្នុងការចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការ IEP។
- សិទ្ធិក្នុងការស្នើសុំជំនួយផ្នែកបកប្រែភាសា របស់ក្រសួង។ លោកអ្នកត្រូវបានគេលើកទឹកចិត្តឱ្យស្នើសុំជំនួយផ្នែកបកប្រែភាសារបស់ក្រសួង នៅពេលណាក៏បាន។ ឧទាហរណ៍ អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា (BCAs) អាចជួយបកប្រែភាសា នៅពេលណាដែលគេត្រូវការ។ លើសពីនេះទៀត លោកអ្នកត្រូវបានគេលើកទឹកចិត្តឱ្យស្នើសុំជំនួយផ្នែកបកប្រែបន្ថែមទៀត បើសិនជាជំនួយនៃការបកប្រែមិនអនុញ្ញាតឱ្យលោកអ្នកចូលរួមដោយមានអត្ថន័យនៅក្នុងដំណើរការ IEP ។ លោកអ្នកអាចធ្វើដូច្នេះបានដោយទាក់ទងទៅអ្នកធ្វើទំនាក់ទំនងផ្នែកអប់រំពិសេស (SEL) ដែលគេបានចាត់តាំងឲ្យទៅសាលារបស់កូនលោកអ្នក។

ដើម្បីជ្រាបពីការពិពណ៌នាពេញលេញអំពីសិទ្ធិរបស់ មាតាបិតា/អាណាព្យាបាល សូមមើលសេចក្តីជូនដំណឹងអំពី នីតិវិធីនៃការការពារសិទ្ធិ។ គេអាចមើលសៀវភៅណែនាំអំពីនីតិវិធីនៃការការពារសិទ្ធិពេញលេញតាមរយៈវ៉ិបសៃដូចខាងក្រោមនេះ៖